## របៀបទាក់ទងជាមួយ CCS ដើម្បីប្រើប្រាស់សិទ្ធិរបស់លោកអ្នក

ប្រសិនបើលោកអ្នកចង់ប្រើនូវសិទ្ធិស្តីអំពីឯកសិទ្ធិរបស់លោកអ្នកដែលបានជំរាបជូននូវតាមការប្រកាសជំរាបដំណឹងនេះ, សូមមេត្តាទូរស័ព្ទ ឬសរសេរលិខិតទៅកាន់កម្មវិធី CCS ដែលមាននៅតាមខោនធីរបស់លោកអ្នក។ អាស័យដ្ឋាននិង លេខទូរស័ព្ទនៃកម្មវិធី CCS ក្នុងខោនទីរបស់លោកអ្នកមានរាយក្នុងបញ្ជីភ្ជាប់មកជាមួយនេះ

## ដើម្បីធ្វើការត៏វ៉ា

ប្រសិនបើលោកអ្នកយល់ថាគេមិនបានរក្សាការពារឯកសិទ្ធិនៃកូនរបស់លោកអ្នកនោះទេ, ហើយលោកអ្នកមានបំណងចង់ធ្វើការត៏វ៉ា, សូមទូរស័ព្ទឬសរសេរមកយើងតាមរយៈ

| |
|---|
| Privacy Officer<br>Department of Health Care Services<br>P.O. Box 997413<br>MS 0010<br>Sacramento, CA 95899-7413<br>(916) 445-4646<br>or (877) 735-2929 TTY/TDD |

ឬ

| |
|---|
| Secretary of the U.S. Department of Health and Human Services<br>Office for Civil Rights<br>Attention: Regional Manager<br>50 United Nations Plaza, Room 322<br>San Francisco, CA 94102<br><br>ពត៌មានបន្ថែមសូមទូរស័ព្ទទៅលេខៈ<br>(800) 368-1019<br>ឬ<br>U.S. Office for Civil Rights at<br>(866) OCR-PRIV (866-627-7748)<br>or (866) 788-4989 TTY |

## ពុំមានការសងសឹកផ្តន្ទា

CCS មិនអាចកាត់ឬដកនូវកំរៃលើការថៃទាំសុខភាពរបស់កូនលោកអ្នកនោះឡើយ ឬក៏មិនមានធ្វើអ្វីឲ្យប៉ះទង្គិចដល់រូបលោកអ្នកក្នុងមធ្យោបាយអ្វីទាំងអស់ចំពោះលោកអ្នកដែលបានប្រើប្រាស់លើការត៏វ៉ាទាមទារនូវសិទ្ធិរក្សាឯកសិទ្ធិរបស់លោកអ្នកទៅតាមការប្រកាសជំរាបនៅក្នុងដំណឹងទាំងឡាយនេះ។

## កាលបរិច្ឆេទក្នុងការផ្តើមអនុវត្ត

សេចក្តីប្រកាសនៃការអនុវត្តន៍លើឯកសិទ្ធិគឺចាប់ផ្តើម ពីថ្ងៃទី ១៤ ខែមេសា, ឆ្នាំ ២០០៣ ។

## ការប្តូរផ្លាស់លើសេចក្តីប្រកាសចំពោះកិច្ចអនុវត្តន៍នៃឯកសិទ្ធិ

CCS ត្រូវតែគោរពទៅលើសេចក្តីប្រកាសទាំងឡាយនេះ។ ប៉ុន្តែយើងមានសិទ្ធិដើម្បីប្តូរលើការអនុវត្តន៍នៃឯកសិទ្ធិរបស់យើង។ ប្រសិនបើយើងមានការប្តូរផ្លាស់អ្វីណាមួយ, យើងនឹងសរសេរនូវការប្រកាសជំរាបជូនដំណឹងជាថ្មីប្រគល់ជូនដល់លោកអ្នក, ប្រសិនបើលោកអ្នកស្ថិតនៅក្នុងកម្មវិធី CCS នេះ។

## សំណួរ

ប្រសិនបើលោកអ្នកសំណួរណាមួយអំពីសេចក្តីប្រកាសជំរាបជូនដំណឹងនេះ ហើយចង់ទទួលនូវពត៌មានបន្ថែមសូមមេត្តាទាក់ទងនឹង Privacy Officer, ដែលមានលេខទូរស័ព្ទនិងអាស័យដ្ឋានក្នុងសេចក្តីប្រកាសនេះស្រាប់។

---

**ដើម្បីទទួលនូវការប្រកាសជំរាបដំណឹងនេះជាភាសាផ្សេងទៀត,អក្សរសម្រាប់មនុស្សខ្វាក់,អក្សរធំៗ,សម្លេងខ្សែអាត់ឬថាសកុំព្យូទ័រ,សូមមេត្តាទូរស័ព្ទ ឬសរសេរទៅកាន់ Privacy Officer តាមរយៈលេខ និងអាស័យដ្ឋាន ដែលមានជំរាបនៅក្នុងសេចក្តីប្រកាសនេះស្រាប់។**

---

| |
|---|
| **<<< ករណីយសំខាន់ >>>**<br><br>**CCS ពុំមានឯកសារថតចម្លងអំពីពត៌មានសុខភាពឲ្យបានគ្រប់ទាំងអស់នោះទេ។ ប្រសិនបើលោកអ្នកចង់មើល ហើយចង់បានសំណុំឯកសារទាំងនោះ,ឬការប្តូរនៃឯកសារនៃកូនរបស់លោកអ្នក សូមមេត្តាទាក់ទងនឹង វេជ្ជបណ្ឌិត,កន្លែងរក្សាមើលសុខភាព ឬកន្លែងផ្តល់គម្រោងសុខភាពនៃកូនរបស់លោកអ្នក។ ប្រសិនបើកូនរបស់ប្រើប្រាស់នូវ MANAGED CARE PLAN, កន្លែងនោះអាចមានសំណុំរឿងអំពីការបង់ថ្លៃចំណាយព្យាបាល, សូមទាក់ MANAGED CARE PLAN ដើម្បីពិនិត្យមើលឬការថតចម្លងស្តីអំពីការចំណាយលើថ្លៃព្យាបាលទាំងឡាយនានា** |

Department of
Health Care Services

# សារមកពីកម្មវិធីសេវាកម្មសម្រាប់កុមារនៅរដ្ឋកាលីហ្វ័រនីញ៉ា

# CALIFORNIA CHILDREN’S SERVICES (CCS)

# សេចក្តីប្រកាសជំរាបជូនដំណឹងអំពីការអនុវត្តន៍លើឯកសិទ្ធិផ្ទាល់ខ្លួន

---

សេចក្តីប្រកាសនេះគឺរៀបរាប់ពីរបៀបប្រាប់ពត៌មានលើការប្រើប្រាស់នៃសំណុំឯកសារខាងផ្នែកសុខភាព និងបំបិទសំណុំឯកសារឲ្យបានជិត ព្រមទាំងពីរបៀបដើម្បីធ្វើយ៉ាងណាឲ្យបានទទួលនូវដំណឹងលើផ្នែកសុខភាពទាំងឡាយនេះ ។

**សូមមេត្តាអានដោយប្រុងប្រយ័ត្ន។**

---

កម្មវិធី CCS ត្រូវតែរក្សាទុកនូវពត៌មាននៃផ្នែកសុខភាពរបស់ក្មេងដែលយើងបំរើក្នុងលក្ខណៈជាឯកជនបំផុត។ គឺរាប់ទាំងពីពត៌មានដាក់សុំទទួលនូវកំរៃអំពី CCS, ពត៌មាននៃផ្នែកសុខភាពផ្ទាល់ខ្លួន។ CCS ត្រូវតែជំរាបលោកអ្នកឲ្យបានដឹងអំពីការប្រើប្រាស់និងការចែកចាយ ឬ "ការបំបិទ" ចំពោះពត៌មាននានារបស់កុមារដែលយើងធ្វើកិច្ចការបំរើជូនទាំងឡាយនេះ។

## របៀបដែលយើងប្រើប្រាស់ចែកចាយនូវពត៌មានរបៀបណា

ឈ្មោះរបស់ក្មេង,អាស័យដ្ឋាន,ពត៌មានផ្ទាល់ខ្លួនរបស់ក្មេង,ប្រវត្តិនៃការព្យាបាលជម្ងឺ,ការពិនិត្យជម្ងឺ,និងកិច្ចការបំរើខាងផ្នែកសុខភាពដែលយើងរៀបចំបំរើដល់ក្មេងនោះតាមរយៈកម្មវិធី CCS នឹងចែកចាយក្នុងមូលហេតុចំបងដែលទាក់ទងនឹងដំណើរកិច្ចការរបស់ CCS ។ មូលហេតុទាំងមានដូចជា:

- ការសម្រេចលើការទទួលកំរៃបានអំពី CCS ដែរឬយ៉ាងណា
- ការសម្រេចថានឹងត្រូវបង់ថ្លៃខ្លះដើម្បីទទួលកំរៃអំពី CCS បានឬយ៉ាងណា
- ដើម្បីឲ្យដឹងថាតើអាចទទួលកំរៃបានពី Medi-Cal ឬ Healthy Families ហើយឲ្យដឹងថាតើគេមានធានារ៉ាប់រងសុខភាពដែរឬយ៉ាងណា
- **សម្រាប់ការព្យាបាល:** ការយល់ព្រមដើម្បីឲ្យធ្វើការព្យាបាលដល់ក្មេងដូចជាការពិនិត្យ,ព្យាបាល,មើលអាការរោគ CCS ប្រហែលជាធ្វើការយល់ស្របនូវកិច្ចការទាំងនោះទុកជាមុន។ ដើម្បីផ្តល់ការអនុញ្ញាត្តិនេះ CCS ប្រហែលទទួលឬត្រូវចែកចាយពត៌មានដល់អ្នកមើលការខុសត្រូវគិតគូរយ៉ាងដើម្បីក្មេងនោះទទួលការបំរើដែលត្រូវការចាំបាច់។
- **សម្រាប់ការបង់ថ្លៃព្យាបាល:** CCS និងអ្នកផ្សេងទៀតដែលធ្វើការពិនិត្យសារឡើងវិញជាមួយយើងដើម្បីយល់ព្រមសងត្រឡប់ទៅកាន់កន្លែងដែលគេទារលុយដូចជាមកពីវេជ្ជបណ្ឌិតឬកន្លែងពិនិត្យព្យាបាលជាដើម។ CCS ប្រហែលជាចែកចាយពត៌មាននោះជាមួយវេជ្ជបណ្ឌិតឬកន្លែងព្យាបាលនោះដែលបានផ្ញើលិខិតមកទារលុយអំពី CCS។ CCS ក៏អាចផ្ញើលិខិតទារលុយអំពីកន្លែងផ្តល់ធានាលើសុខភាពឬក្រុមណាដទៃទៀតដើម្បីធ្វើការបង់ការចំណាយដែលក្មេងទទួលនូវការព្យាបាល។
- **សម្រាប់កកិច្ចការអនុវត្តន៍នៃការព្យាបាល:** CCS អាចប្រើប្រាស់លើការពិតនៃសុខភាពរបស់ក្មេង និងការព្យាបាលនូវសុខភាពគឺធ្វើយ៉ាងណាឲ្យក្មេងនោះទទួលបាននូវគុណភាពទៅលើការពិនិត្យព្យាបាល។ CCS ក៏អាចប្រើសម្រាប់ធ្វើការពិនិត្យផ្ទៀងឬស៊ើបអង្កេតលើការកេងបន្លំចំពោះវេជ្ជបណ្ឌិត និងកន្លែងព្យាបាល និងសម្រាប់ធ្វើគម្រោងការនិងចាត់ចែងដំណើរការនៃកម្មវិធី CCS ។

## កិច្ចការខ្លះទៀតដែលយើងនឹងអាចប្រើប្រាស់នូវពត៌មានរបស់ក្មេងនោះ

កម្មវិធី CSS អាចនឹងធ្វើការប្រើប្រាស់ ឬផ្តល់ពត៌មានដែលយើងមានទាំងឡាយរបស់ក្មេងនោះគឺសម្រាប់លើកិច្ចការឲ្យដឹងថាក្មេងទទួលបាននូវកម្មវិធី CCS និងពត៌មានលើផ្នែកសុខភាពក្នុងមូលហេតុដូចជា:

- ដើម្បីទូរស័ព្ទឬសរសេរជំរាបដំណឹងចំពោះក្មេងឲ្យបានជ្រាបអំពីកំរៃដែលគេទទួលអំពីកម្មវិធី CCS
- ដល់មនុស្សក្នុងគ្រួសាររបស់ក្មេងដើម្បីធ្វើការព្យាបាលឬជួយបង់ថ្លៃ
- សម្រាប់ប្រើប្រាស់តាមផ្លូវច្បាប់,ដូចជានៅពេលដែលតុលាការតម្រូវ។
- សម្រាប់ធ្វើការសិក្សាស្រាវជ្រាវដែលធ្វើតាមច្បាប់តម្រូវឲ្យបានគ្រប់គ្រាន់,ដូចជាការសិក្សាអំពីកិច្ចការពារនៃជម្ងឺ។
- ដើម្បីស្រាវជ្រាវនៅពេលបាត់ដំណឹងអំពីក្មេងនោះ,ដូចជាបញ្ជីនៃបញ្ហានានានៃផ្នែកសុខភាពដែលតែងតែកើតមានចំពោះក្មេងដែលស្ថិតនៅក្នុងកម្មវិធី CCS ។
- ក្នុងមូលហេតុដែលតម្រូវឡើងតាមផ្លូវច្បាប់, ដែលអាចធ្វើការចែកចាយនូវពត៌មាននៃផ្នែកសុខភាពរបស់ក្មេង។

យើងក៏អាចចែកចាយនូវពត៌មាននេះទៅដល់អង្គការដែលជួយចាត់ចែងនូវកម្មវិធីរបស់យើង, ដូចជាកន្លែងបង់សំណងទារលុយជាដើម។ ប្រសិនបើជាយើងធ្វើ យើងក៏គិតគូរយ៉ាងហ្មត់ចត់ដើម្បីរក្សាការពារនូវពត៌មានទាំងឡាយដែលយើងបានចែកចាយទៅនោះ ។

ច្បាប់ខ្លះដែលចែងឡើងដោយរដ្ឋគឺធ្វើឡើងក្នុងករឹតចំពោះការចែកចាយទាំងឡាយដូចមានខាងលើនេះ។ ឧទាហរណ៍ដូចជាច្បាប់គឺមិនត្រូវចែកចាយនូវពត៌មានដូចជាមានជម្ងឺ HIV/AIDS ឬការពិនិត្យព្យាបាលលើផ្នែកខួរក្បាល,ភាពពិការ,និងការព្យាបាលលើផ្នែកគ្រឿងញៀនឬសុរា។ យើងនឹងគោរពទៅលើច្បាប់ចែងទាំងនោះ។

## កំណត់

ប្រសិនបើក្មេងនោះកំពុងទទួល MEDI-CAL, ច្បាប់ពុំមានអនុញ្ញាត្តិឲ្យចែកចាយនូវពត៌មានដូចជំរាបខាងលើនោះទេ។ ច្បាប់របស់ MEDI-CAL និយាយថាពត៌មានអាចចែកចាយចំពោះអ្វីដែលទាក់ទងនឹងដំណើរការរបស់ MEDI-CAL តែប៉ុណ្ណោះ។

## នៅពេលចាំបាច់ក្នុងការសរសេរលិខិតអនុញ្ញាត្តិ

CCS ត្រូវតែសរសេរសុំការអនុញ្ញាត្តិសិទ្ធិអំពីមាតាបិតារបស់ក្មេងអាណាព្យាបាល,ឬក្មេងផ្ទាល់ចំពោះក្មេងនោះរស់នៅដោយខ្លួនឯង មុននឹងហ៊ានធ្វើការចែកចាយពត៌មានលើការទទួលនូវកម្មវិធី CCS និងពត៌មានលើផ្នែកសុខភាពរបស់ក្មេងដែលនឹងកើតមានឡើងចំពោះអ្វីមិនបានចែងក្នុងការប្រកាសជំរាបដំណឹងនេះ។ ប្រសិនបើលោកអ្នកបានសរសេរទៅ CCS ផ្តល់សិទ្ធិលើការចែកចាយពត៌មានក្មេង, ហើយក៏អាចមានសិទ្ធិសរសេរដើម្បីទាមទារត្រឡប់មកវិញបាននូវគ្រប់ពេលវេលា។

## សិទ្ធិនៃឯកសិទ្ធិរបស់លោកអ្នក

តាមច្បាប់លោកអ្នកមានសិទ្ធិនឹង:

- អាចពិនិត្យឬទទួលនូវសំណៅឯកសារពត៌មាននៃសុខភាពដែល CCS មានទាំងឡាយនោះ ដូចជា:
- លោកអ្នកអាចមានសិទ្ធិដើម្បីធ្វើការកែតម្រូវទៅលើសំណុំឯកសារនៃពត៌មានរបស់កូនលោកអ្នកប្រសិនជាលោកអ្នកយល់ថាពត៌មាននោះមិនត្រូវឬខ្វះខាតកន្លែងណាមួយហើយប្រសិនបើ CCS យល់ព្រម។ ប្រសិនបើ CCS មិនស្របទេលោកអ្នកនឹងទទួលសំបុត្របញ្ជាក់សួរអំពីហេតុអ្វីបានជាត្រូវបញ្ចូលពត៌នោះក្នុងសំណុំឯកសារសុខភាពរបស់ក្មេង។
- លោកអ្នកមានសិទ្ធិដើម្បីទាមទារសួររកបញ្ជីឲ្យបានដឹងថាតើនរណាដែលមានសំណុំឯកសារសុខភាពរបស់ក្មេងអំពី CCS។ បញ្ជីនោះពុំមានរាប់បញ្ចូលនូវពត៌មានសុខភាពផ្ទាល់របស់ក្មេងទេចំពោះអ្វីទាំងឡាយដែលលោកអ្នកជាមាតាបិតា, អាព្យាបាល,ឬក្មេងដែលរស់នៅដោយឯងផ្ទាល់បានផ្តល់មក ឬពត៌មានគឺសម្រាប់ចែកចាយពត៌មានសម្រាប់ព្យាបាល,ការចំណាយទៅលើការព្យាបាល,ឬដំណើរចាត់ចែងការរបស់កិច្ចការនៃកន្លែងព្យាបាលនោះទេ។
- លោកអ្នកអាចប្រាប់មក CCS ដើម្បីឲ្យធ្វើការទាក់ទងលោកអ្នកតាមរយៈតែការសរសេរឬតាមអាស័យដ្ឋានផ្សេង,ឬលេខប្រអប់សំបុត្រ,ឬតាមលេខទូរស័ព្ទផ្សេង។ យើងនឹងទទួលនូវសំណូមពរដើម្បីរក្សានូវសន្តិសុខសម្រាប់កូនរបស់លោកអ្នក។
- លោកអ្នកមានសិទ្ធិប្រាប់មក CCS ដើម្បីកុំឲ្យធ្វើការចែកចាយឬការប្រើប្រាស់ចំពោះពត៌មានឯកសារសុខភាពផ្ទាល់របស់ក្មេងនោះ។ CCS អាច មានសិទ្ធិធ្វើការជំទាស់លើសំណូមពរទាំងនោះ។
- លោកអ្នកមានសិទ្ធិដើម្បីទទួលនូវសំណៅនៃឯកសារលើការជំរាបនូវពត៌មាននេះស្តីអំពីការអនុវត្តន៍ការពារសិទ្ធិនៃឯកសិទ្ធិនៅពេលណាដែលលោកអ្នកមានបំណងនឹងធ្វើការទាមទារ បានគ្រប់ពេលវេលា។ លោកអ្នកក៏អាចរកឃើញនូវពត៌មាននេះតាមរយៈបណ្តាញវ៉ិបសាយ គឺ: WWW.DHCS.CA.GOV/SERVICES/CCS.